ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យមេគង្គកម្ពុជា**

# ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរំកិល០៣ឆ្នាំ នៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសាកលវិទ្យាល័យមេគង្គកម្ពុជា ពីឆ្នាំ២០១២~២០១៥

## ១. សេចក្តីផ្តើម

សាកលវិទ្យាល័យមេគង្គកម្ពុជា ដែលបានទទួលស្គាល់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាយោងតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ បានបង្កើតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅក្នុងឆ្នាំ២០០៥ ដោយមានការទទួលស្គាល់ពីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ១៤៩២អយក. ប្រក ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៥។ បន្ទាប់ពីបានបង្កើតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅក្នុងសាកលវិទ្យាល័យមេគង្គកម្ពុជា ដេប៉ាតឺម៉ង់នេះបានខិតខំយ៉ាងខ្លាំងខ្លាដែលក្នុងនោះនៅក្នុងឆ្នាំសិក្សា ២០០៥~២០០៦ សាកលវិទ្យាល័យមេគង្គកម្ពុជាបានទទួលបាននូវការទទួលស្គាល់ជាបណ្តោះអាសន្នពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំពោះនិស្សិត ដែលបានបញ្ចប់យ៉ាងជោគជ័យសំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅក្នុងសាកលវិទ្យាល័យមេគង្គកម្ពុជា។ បន្ថែមពីនេះទៀត សាកលវិទ្យាល័យក៏បានទទួលបានការទទួលស្គាល់ពេញសិទ្ធិពីឆ្នាំ២០០៦~២០០៩ ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

## ២. យុទ្ធសាស្ត្រនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

### ២.១ ទស្សនវិស័យ

សាកលវិទ្យាល័យមេគង្គកម្ពុជា នឹងជាសាកលវិទ្យាល័យឈានមុខគេក្នុងចំណោមសាកលវិទ្យាល័យឈានមុខគេ៥ ក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជាដែលទទួលស្គាល់ដោយសហគមន៍ជាតិនិងអន្តរជាតិឆ្នាំ២០១៥។

## ២.២ បេសកកម្ម

- បុគ្គលិកនិងសាស្ត្រាចារ្យប្រកបដោយគុណភាព
- ជំរុញលើកទឹកចិត្តបុគ្គលិកនិងបណ្តុះនិស្សិតឲ្យមានស្មារតីស្វ័យសិក្សានិងប្រឹងប្រែងរៀនសូត្រដោយខ្លួនឯង
- ធ្វើឲ្យមានគុណភាពសិក្សាក្នុងបរិបទជាតិនិងអន្តរជាតិ
- ជាកន្លែងប្រកបដោយគុណភាពសំរាប់អ្នកសិក្សា

## ២.៣ គោលដៅ

- និស្សិតនឹងទទួលបានចំណេះដឹងមូលដ្ឋានដ៏ទូលំទូលាយនៅពេលបញ្ចប់ឆ្នាំសិក្សាមូលដ្ឋាន
- នឹងផ្តល់សារៈប្រយោជន៍និងប្រសិទ្ធភាពខ្ពស់សំរាប់ជីវិតប្រចាំថ្ងៃ
- មានស្តង់ដារលើប្រព័ន្ធគ្រប់គ្រងនិងកម្មវិធីសិក្សា

## ២.៤ វត្ថុបំណង

- ធ្វើឲ្យមានកម្មវិធីសិក្សាស្របទៅនឹងតម្រូវការការងារក្នុងវិស័យសាកលភាវូបនីយកម្ម
- ធានាបានគុណភាពសិក្សាដែលស្របតាមគោលការណ៍របស់គ.ទ.ក និង អ.យ.ក
- ទទួលស្គាល់ពីសហគមន៍អ្នកសិក្សាជាតិនិងអន្តរជាតិ

## ២.៥ សកម្មភាពជាក់លាក់

- គ្រប់គ្រងទិន្នន័យឲ្យបានច្បាស់លាស់
- គាំទ្រជាធនធានសំរាប់ការបង្រៀននិងការរៀន
- ភ្ជាប់ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់
- ជ្រើសរើស វាយតម្លៃ និង លើកទឹកចិត្តសាស្ត្រាចារ្យ
- តាមដាន និង ត្រួតពិនិត្យជាប្រចាំនូវកិច្ចការដែលបានដាក់ជូន
- ផ្តល់ការណែនាំនិងផ្តល់ការប្រឹក្សាដល់និស្សិត
- បង្កើតមជ្ឈមណ្ឌលសំរាប់ការសិក្សាល្អបំផុត
- បង្កើនទំនាក់ទំនងជាមួយគ្រឹះស្ថានអប់រំក្នុងនិងក្រៅប្រទេស

## ២.៦ យុទ្ធសាស្រ្ត

១. អភិវឌ្ឍន៍រចនាសម្ព័ន្ធគ្រប់គ្រង
២. អភិវឌ្ឍន៍កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឲ្យស្របទៅនឹងទីផ្សារជាតិនិងតំបន់
៣. ពង្រឹងបុគ្គលិកនិងគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
៤. អភិវឌ្ឍន៍សេវានិស្សិត និង សេវារដ្ឋបាលសំរាប់និស្សិត
៥. អភិវឌ្ឍន៍ធនធានសិក្សានិងបំពាក់សម្ភារៈសិក្សាទាន់សម័យ
៦. ពង្រីកការផ្សព្វផ្សាយព័ត៌មាន

## ៣. ផែនការសកម្មភាព

ដើម្បីសំរេចបាននូវយុទ្ធសាស្រ្តខាងលើ ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៃសាកលវិទ្យាល័យមេគង្គកម្ពុជាមានផែនការសកម្មភាពដូចតទៅ៖

៣.១ អភិវឌ្ឍន៍រចនាសម្ព័ន្ធគ្រប់គ្រង

| ល.រ | សកម្មភាព | លទ្ធផល | ពេលវេលាកំណត់ | ធនធានចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | អភិវឌ្ឍន៍រចនាសម្ព័ន្ធគ្រប់គ្រង | មានការទទួលខុសត្រូវច្បាស់លាស់ និង មានប្រសិទ្ធភាពការងាររបស់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ខែសីហានៃដើមឆ្នាំសិក្សានីមួយៗ | គោរពទៅតាមនិយាមរបស់គ.ទ.ក | គណៈគ្រប់គ្រងសាកលវិទ្យាល័យនិងដេប៉ាតឺម៉ង់ធនធានមនុស្ស |
| ២ | ពង្រឹងនិងពង្រីកផែនការរបស់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | -ដើម្បីពិនិត្យនិងអភិវឌ្ឍនូវតួនាទីរបស់បុគ្គលិកដេប៉ាតឺម៉ង់<br>-បូកសរុបផែនការឆ្នាំចាស់និងលើកផែនការសំរាប់ឆ្នាំថ្មី | ខែសីហាទៅខែកញ្ញានៃដើមឆ្នាំសិក្សានីមួយៗ | ពេលវេលា បុគ្គលិកដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន គណៈកម្មការផែនការយុទ្ធសាស្ត្រ |
| ៣ | បណ្តុះបណ្តាលបុគ្គលិករបស់ដេប៉ាតឺម៉ង់ | ដើម្បីទទួលបានភាពច្បាស់លាស់នៃការងារនិងសំរេចបានគោលដៅ | ខែកក្កដានៃដើមឆ្នាំសិក្សានីមួយៗ | ថវិកា ពេលវេលានិងបុគ្គលិកចាំបាច់ | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន |

៣.២ អភិវឌ្ឍន៍កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឲ្យស្របទៅនឹងទីផ្សារជាតិនិងតំបន់

| ល.រ | សកម្មភាព | លទ្ធផល | ពេលវេលាកំណត់ | ធនធានចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | រៀបចំប្រជុំគណៈកម្មការជំនាញនិងគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សាសំរាប់កំណត់កម្មវិធីសិក្សាថ្មីនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | -ដើម្បីធ្វើទំនើបកម្មកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>-ប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តកម្មវិធីសិក្សានិងលើកពីផែនការបន្ត | -ខែសីហានៃដើមឆ្នាំសិក្សានីមួយៗ<br>-ខែកញ្ញានៃចុងឆ្នាំសិក្សានីមួយៗ | សាស្ត្រាចារ្យជំនាញនិងសមាជិកនៃគណៈអភិវឌ្ឍន៍កម្មវិធីសិក្សា | គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សានិង ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន |

| | | | | | |
|---|---|---|---|---|---|
| ២ | សិក្សាស្រាវជ្រាវលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ក្នុងចំណោមនិស្សិតគ្រូបង្រៀន និង តំណាងឧស្សាហកម្មជ្រើសរើស | ដើម្បីជំរុញអោយកម្មវិធីសិក្សាឆ្លុះបញ្ចាំងការអប់រំ ជំនាញ និង ចំណេះដឹងចាំបាច់សំរាប់និស្សិតនិងសេចក្តីត្រូវការរបស់ឧស្សាហកម្ម (ទីផ្សារបច្ចុប្បន្ននិងអនាគត) | អំឡុងខែកញ្ញានៃចុងឆ្នាំសិក្សានីមួយៗ | សំនួរ ចម្លើយ ធនធានមនុស្ស ដើម្បីប្រមូល ទិន្នន័យ និង វិភាគ | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដេប៉ាតឺម៉ង់សិក្សាធិការនិង គ្រូថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន |

៣.៣ ពង្រឹងបុគ្គលិកនិងគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

| ល.រ | សកម្មភាព | លទ្ធផល | ពេលវេលាកំណត់ | ធនធានចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | ជ្រើសរើសគ្រូបង្រៀនដែលមានជំនាញ និងបទពិសោធន៍សំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និង ធ្វើកិច្ចសន្យាគ្រូ | -ដើម្បីជ្រើសរើសគ្រូដែលសុទ្ធតែមានបទពិសោធន៍និងជំនាញគ្រប់គ្រាន់ សំរាប់កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>- ធ្វើកិច្ចសន្យាបង្រៀន | ដើមឆ្នាំសិក្សានីមួយៗ ឬ ដើមឆមាសនីមួយៗ | ពេលវេលា ទម្រង់នៃការវាយតម្លៃ ការផ្សព្វផ្សាយជ្រើសរើសគ្រូបង្រៀន និងការវាយតម្លៃដើម្បីជ្រើសរើសបេក្ខជន | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់ធនធានមនុស្ស និងផ្នែកពាក់ព័ន្ធ |
| ២ | ពង្រឹងនិងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពនិងភាពមានទំនុកចិត្តរបស់គ្រូបង្រៀនក្នុងការបង្រៀន | ដើមឆ្នាំសិក្សានីមួយៗ ឬ ដើមឆមាសនីមួយៗ | ពេលវេលា ទីកន្លែង ថវិកា និង សម្ភារៈសំរាប់កម្មសិក្សា | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |
| ៣ | ធ្វើវង្វាយតម្លៃទៅលើគ្រូបង្រៀនដោយនិស្សិតផ្ទាល់ ជូនលិខិតសរសើរចំពោះ | -ដើម្បីវង្វាយតម្លៃទៅលើការបង្រៀនរបស់គ្រូបង្រៀននិង | - អំឡុងរៀងរាល់មួយខែមុនបញ្ចប់ | ពេលវេលា ការចូលរួមរបស់ | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូល |

| | | | | | |
|---|---|---|---|---|---|
| | លោកគ្រូអ្នកគ្រូ (ដែលមានស្នាដៃល្អប្រចាំឆ្នាំ) | ផ្តល់ការស្តាបនាដល់ការបង្រៀនរបស់គ្រូ<br>- ផ្តល់លិខិតសរសើរ | ឆមាសនីមួយៗ<br>-អំឡុងពេលបញ្ចប់ឆ្នាំសិក្សានីមួយៗ | និស្សិត ថវិកា និង មន្ត្រីរដ្ឋបាល | ដ្ឋាននិងដេប៉ាតឺម៉ង់ធនធានមនុស្ស |
| ៤ | ពិនិត្យនិងតាមដានវត្តមាន និង ភាពយឺតយ៉ាវលោកគ្រូអ្នកគ្រូ | -បង្កើនភាពងាយស្រួលនៃទំនាក់ទំនងរវាងគ្រូនិងសិស្ស<br>-បង្កើននូវការទទួលខុសត្រូវរបស់គ្រូបង្រៀន | រៀងរាល់ពេលនៃការបង្រៀនក្នុងឆមាសនីមួយៗ | ពេលវេលា ភាពសកម្មនៃបុគ្គលិក | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |

## ៣.៤ អភិវឌ្ឍន៍សេវានិស្សិត និង សេវារដ្ឋបាលសំរាប់និស្សិត

| ល.រ | សកម្មភាព | លទ្ធផល | ពេលវេលាកំណត់ | ធនធានចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | ធ្វើបញ្ជីនូវចំនួននិស្សិតដែលបានប្រឡងជាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ដើម្បីកំណត់ឲ្យបាននូវអត្តសញ្ញាណនៃនិស្សិតដែលបានបញ្ចប់កម្មវិធីសិក្សាថ្នាកឆ្នាំសិក្សាមូលដ្ឋាន | អំឡុងពេលពីរសប្តាហ៍បន្ទាប់ពីការប្រឡងបានបញ្ចប់ | ពេលវេលា និង ថវិកាចាំបាច់ | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និង ដេប៉ាតឺម៉ង់សិក្សាធិការ |
| ២ | ផ្តល់នូវវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ដើម្បីផ្តល់ការទទួលស្គាល់ដល់និស្សិតដែលបានបញ្ចប់ដោយជោគជ័យ | អំឡុងពេលបីសប្តាហ៍បន្ទាប់ពីការប្រឡងបានបញ្ចប់នៃឆ្នាំសិក្សានីមួយៗ | ទីកន្លែងនិងមានការចូលរួមពីភ្ញៀវកិត្តិយស | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន |

| | | | | | |
|---|---|---|---|---|---|
| ៣ | ពិនិត្យនិងតាមដានវត្តមានរបស់និស្សិត | ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវភាពទៀងទាត់នៃការមករៀន និង កំនត់នូវការយល់ដឹងរបស់និស្សិត | រៀងរាល់ម៉ោងសិក្សានៃឆមាសនីមួយៗ | គ្រូបង្រៀនប្រចាំថ្នាក់នីមួយ និង ភាពសកម្មនៃបុគ្គលិក | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |
| ៤ | ត្រួតពិនិត្យការប្រឡងបញ្ចប់ប្រចាំឆមាសនីមួយៗ | -ដើម្បីទទួលបាននូវសមត្ថភាពពិតប្រាកដរបស់និស្សិតផ្ទាល់<br>-ដើម្បីឲ្យនិស្សិតអាចមានលទ្ធភាពបន្តការសិក្សាទៅមុខទៀត | ពេលប្រឡងបញ្ចប់នៃឆមាសនីមួយៗ | ភាពសកម្មនៃបុគ្គលិក និង សម្ភារៈមួយចំនួន | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |
| ៥ | ការចេញលទ្ធផលនៃការប្រឡងរបស់និស្សិត | ដើម្បីឲ្យនិស្សិតទទួលបាននូវភាពទុកចិត្តនៃការសិក្សារបស់ខ្លួន | ពេលបីសប្តាហ៍បន្ទាប់ពីប្រឡងបញ្ចប់ឆមាសនីមួយៗ | ពេលវេលា សម្ភារៈមួយចំនួន | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |

៣.៥ អភិវឌ្ឍន៍ធនធានសិក្សានិងបំពាក់សម្ភារៈសិក្សាទាន់សម័យ

| ល.រ | សកម្មភាព | លទ្ធផល | ពេលវេលាកំណត់ | ធនធានចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | ធ្វើបញ្ជីសារពើភ័ណ្ឌទៅលើសម្ភារៈរូបវន្តដែលបម្រើដល់កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ដើម្បីកំណត់នូវសម្ភារៈរូបវន្តដែលអាចបម្រើការដល់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ពេលពីរសប្តាហ៍បន្ទាប់ពីបញ្ចប់ឆមាសនីមួយៗ | ពេលវេលានិងធនធានមនុស្សដែលមានសមត្ថភាពសម្រាប់វាយតម្លៃទៅលើសម្ភារៈរូបវន្ត | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ប្រធានដេប៉ាតឺម៉ង់សិក្សាធិការ |

| | | | | | |
|---|---|---|---|---|---|
| ២ | កំណត់អំពីសម្ភារៈរូបវន្តដែលនឹងត្រូវបម្រើការដល់កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ដើម្បីកំណត់ឲ្យច្បាស់លាស់ថាសម្ភារៈរូបវន្តពិតជាបម្រើដល់កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ពេលមួយសប្តាហ៍បន្ទាប់ពីធ្វើបញ្ជីសារពើភ័ណ្ឌ | ពេលវេលា និងធនធានមនុស្សចាំបាច់ | ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ប្រធានដេប៉ាតឺម៉ង់សិក្សាធិការ |
| ៣ | បង្កើតប្រព័ន្ធគ្រប់គ្រងបណ្ណាល័យនិងអភិវឌ្ឍន៍សមត្ថភាពបណ្ណារក្ស | -ដើម្បីគ្រប់គ្រងឲ្យមានប្រសិទ្ធភាពនៅក្នុងបណ្ណាល័យ<br>-ពង្រឹងការគ្រប់គ្រងរបស់បណ្ណារក្ស | អំឡុងពេលមុនចាប់ផ្តើមឆ្នាំសិក្សានីមួយៗ | ពេលវេលា និងថវិកាចំណាយសំរាប់ការបណ្តុះបណ្តាល | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |
| ៤ | អភិវឌ្ឍន៍នូវបច្ចេកវិទ្យាទំនើបដើម្បីគាំទ្រដល់ការសិក្សាស្រាវជ្រាវ | បង្កភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិត | រៀងរាល់ឆមាសនីមួយៗ | ថវិកានិងធនធានមនុស្សដែលមានសមត្ថភាព | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ និង ដេប៉ាតឺម៉ង់គណនេយ្យ |

៣.៦ ពង្រីកការផ្សព្វផ្សាយព័ត៌មាន

| ល.រ | សកម្មភាព | លទ្ធផល | ពេលវេលាកំណត់ | ធនធានចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | ចុះផ្សព្វផ្សាយព័ត៌មានចំពោះសិស្សប្រឡងសញ្ញាបត្រទុតិយភូមិ | ដើម្បីឲ្យសិស្សមធ្យមសិក្សាទុតិយភូមិជ្រាបច្បាស់អំពីកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ពេលប្រឡងសញ្ញាបត្រទុតិយភូមិ | ពេលវេលា ថវិកាចំណាយក្នុងការផ្សព្វផ្សាយ | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់ពាក់ព័ន្ធ |
| ២ | ធ្វើសិក្ខាសាលាអំពីការប្រឡងអាហារូប | ដើម្បីឲ្យសិស្សនិស្សិតយល់ | ខែសីហាឬកញ្ញា | ទីកន្លែងនិងថវិកា | ប្រធានដេប៉ាតឺម៉ង់ |

| | | | | | |
|---|---|---|---|---|---|
| | ករណ៍របស់សាកលវិទ្យាល័យមេគង្គកម្ពុជា | ច្បាស់អំពីការប្រឡងអាហារូបករណ៍ | នៃដើមឆ្នាំសិក្សានីមួយៗ | | ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន |
| ៣ | ប្រឡងជ្រើសរើសអាហារូបករណ៍ប្រចាំឆ្នាំ | ដើម្បីទទួលបាននិស្សិតដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីសិក្សាកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ខែកញ្ញានៃដើមឆ្នាំសិក្សានីមួយៗ | ទីកន្លែងនិងថវិកា និងធនធានមនុស្ស | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ |
| ៤ | រៀបចំវគ្គបំពាក់បំប៉នជូនចំពោះនិស្សិតថ្មីអំពីបទបញ្ជាផ្ទៃក្នុង ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ផែនការយុទ្ធសាស្ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ដើម្បីឲ្យនិស្សិតថ្មីយល់ច្បាស់អំពីបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យពីការសិក្សារៀនសូត្រតាមរបៀបមហាវិទ្យាល័យ និងពីកម្មវិធីសិក្សា និង ផែនការយុទ្ធសាស្ត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន | ដើមខែតុលានៃដើមឆ្នាំសិក្សានីមួយៗ | ទីកន្លែង ថវិកា គ្រូបង្រៀន សម្ភារៈឧបទេសដែលចាំបាច់មួយចំនួន | ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននិងដេប៉ាតឺម៉ង់សិក្សាធិការ និង ដេប៉ាតឺម៉ង់គណនេយ្យ |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

**សាកលវិទ្យាធិការ**